អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 25-Jan-2018, 13:14
CMS/CFO: Sann Rada

# សំណើសុំការកែតម្រូវ

**សំណុំរឿងលេខ៖** 002/19-09-2007-ECCC/TC

| កែលើឯកសារលេខ៖ | ERN(s): | កាលបរិច្ឆេទ៖ | ប្រភេទកំណែ៖ |
|---|---|---|---|
| E3/1339 | 01194843-01194848 | 22/01/2018 | ☐ កែលើឯកសារដើម<br>☒ កែលើឯកសារបកប្រែ<br>☐ រៀបចំចាត់ថ្នាក់ឡើងវិញ |

**មូលហេតុនៃការកែតម្រូវ៖**

ជំនួសឯកសារមិនទាន់កែតម្រូវដោយឯកសារដែលបានកែតម្រូវរួច។

**សេចក្តីលម្អិតនៃការកែតម្រូវ៖**

ស្នើដោយ៖ អង្គភាពបកប្រែភាសា ហត្ថលេខា៖

បានទទួលការឯកភាពពីក្រឡាបញ្ជី(ចំពោះឯកសារដើម)៖ ហត្ថលេខា៖

បានទទួលការឯកភាពពីអង្គភាពបកប្រែភាសា(ចំពោះការបកប្រែ)៖ ហត្ថលេខា៖

[ERN 00168349]

**គណៈប្រតិភូចិន ធ្វើទស្សនកិច្ចនៅតំបន់កំពង់សោម ថ្ងៃទី១២ ខែធ្នូ**

BK140345Y សេវាព័ត៌មានក្នុងប្រទេស, ប្រទេសកម្ពុជា ម៉ោង២៣00 GMT ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ១៩៧៧ BK

[អត្ថបទ] កាលពីព្រឹកថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៧៧ សមមិត្ត Chen Yung-Kuei សមាជិកការិយាល័យនយោបាយនៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តចិន និងជាឧបនាយករដ្ឋមន្ត្រីនៃក្រុមប្រឹក្សារដ្ឋ និងសមមិត្តចិនដទៃទៀត បានធ្វើទស្សនកិច្ចនៅក្រុងកំពង់សោម។ ពួកគាត់ ត្រូវបានរួមដំណើរដោយសមមិត្ត ប៉ុល ពត លេខាបក្សកុម្មុយនីស្តកម្ពុជា និងជានាយករដ្ឋមន្ត្រី និងសមមិត្តអៀង សារី និងជួន ជឿន។ នៅទីនោះ សមមិត្ត Chen Yung-Kuei និងសមមិត្តដទៃទៀត ត្រូវបានទទួលស្វាគមន៍ដោយសមមិត្តមុត លេខាបក្សកុម្មុយនីស្តកម្ពុជាក្រុងកំពង់សោម និងជាប្រធានគណៈកម្មាធិការបម្រើប្រជាជនក្រុងកំពង់សោម, សមមិត្ត គ្រិន អនុលេខាបក្សកុម្មុយនីស្តកម្ពុជាក្រុងកំពង់សោម, សមមិត្ត ឡាញ សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជាក្រុងកំពង់សោម, កម្មាភិបាលថ្នាក់ភូមិភាគ, ថ្នាក់តំបន់ និងថ្នាក់ស្រុក និងកម្មាភិបាលមកពីមន្ទីរ និងការិយាល័យនានា។

នៅតាមទៅកន្លែងស្នាក់នៅ កម្មាភិបាលរបស់យើង ត្រូវបានស្វាគមន៍យ៉ាងកក់ក្ដៅ ពីសំណាក់ប្រជាជនរាប់ពាន់នាក់ដែលកាន់ទង់ជាតិនៃប្រទេសទាំងពីរ ជាមួយនឹងផ្កាចម្រុះពណ៌ ដែលបង្ហាញពីសេចក្ដីរីករាយ និងមនោសញ្ចេតនាក្នុងបរិយាកាសភាតរៈបដិវត្តន៍ដ៏ជ្រាលជ្រៅ។ ផ្លូវនានានៅក្នុងទីក្រុង ត្រូវបានតុបតែងដោយដាក់ទង់ជ័យ និងបដា ដែលសរសេរពាក្យស្លោកជាភាសាកម្ពុជា និងចិន ថា “ជយោ! មិត្តភាពបដិវត្តន៍ និងសាមគ្គីភាពយោធានៃកម្ពុជា-ចិន” និង “ស្វាគមន៍យ៉ាងកក់ក្ដៅចំពោះសមមិត្ត Chen Yung-Kuei”។

នៅពេលរសៀល ថ្ងៃដដែលនោះ សមមិត្ត Chen Yung-Kuei និងសមមិត្តចិនដទៃទៀត រួមដំណើរដោយលេខាគណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា, សមមិត្តអៀង សារី, ជួន ជឿន, មុត, គ្រិន និងឡាញ បានធ្វើដំណើរតាមនានា ទៅទស្សនាកោះមួយចំនួននៅក្នុងដែនទឹកកម្ពុជា។

Original EN: 00168307-00168399
[Translated: [00168349], [00168372-00168373]

Formatted

Formatted

Formatted

Deleted: *Unrevised translation. A revised translation will be provided upon request.*

សមមិត្តចិនរបស់យើង ក៏បានទស្សនាកន្លែងសាងសង់នាវានៅកំពង់សោម។ កន្លែងសាងសង់នាវានេះ សង់ពីឈើស្ទើរតែទាំងស្រុង និងជាលទ្ធផលនៃការឆ្នៃប្រឌិត ឯករាជ្យភាព អធិបតេយ្យភាព និងភាពម្ចាស់ការលើខ្លួនឯងនៃកម្មករបដិវត្តន៍របស់ ប.ក.ក។ សមមិត្តចិន ធ្វើការសង្កេតដោយមានការចាប់អារម្មណ៍នឹងបច្ចេកទេសសាងសង់នាវាឈើរបស់កម្មករយើង និងបានសំដែងការកោតសរសើរចំពោះការឆ្នៃប្រឌិត ឯករាជ្យភាព អធិបតេយ្យភាព និងភាពម្ចាស់ការលើខ្លួនឯង ជាភាតរៈ។

នៅល្ងាចថ្ងៃទី១២ ខែធ្នូ គណៈកម្មាធិការ ប.ក.ក ក្រុងកំពង់សោម និងគណៈកម្មាធិការបម្រើប្រជាជនក្រុងកំពង់សោម បានរៀបចំពិធីលៀងសាយភោជន៍ដ៏អធិកអធមមួយ ដែលជាការផ្តល់កិត្តយសជូនសមមិត្ត Chen Yung-Kuei និងសមមិត្តចិនដទៃទៀត។ ពិធីលៀងសាយភោជន៍ បានប្រព្រឹត្តទៅក្នុងបរិយកាសកក់ក្តៅ និងស្និទ្ធស្នាល។ ក្នុងអំឡុងពិធីលៀងសាយភោជន៍ សមមិត្ត មុត និងសមមិត្ត Chen Yung-Kuei បានលើកកែវស្រាប្រសិទ្ធពរដល់មិត្តភាពបដិវត្តន៍ និងសាមគ្គីភាពយោធាដ៏ឧត្តុង្គឧត្តមរវាងបក្សទាំងពីរ និងប្រជាជន និងប្រទេសទាំងពីរ។

Formatted
Deleted: ,
Formatted: Catalan
Deleted: ,
Formatted
Deleted: ,
Formatted: Catalan
Deleted: ,
Formatted
Formatted

Deleted: *Unrevised translation. A revised translation will be provided upon request.*

[ERN 00168372-00168373]

**គណៈប្រតិភូសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ (LPDR) ដឹកនាំដោយ Souphanouvong បញ្ចប់ ដំណើរទស្សនកិច្ច ធ្វើមាតុភូមិនិវត្តន៍នៅថ្ងៃទី២០ ខែធ្នូ**

**ការច្រៀងចម្រៀង និងរាំរបាំ**

BK200912Y សេវាព័ត៌មានក្នុងប្រទេស, ប្រទេសកម្ពុជា ម៉ោង០៤00GMT ថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៧៧ BK

[អត្ថបទ] កាលពីល្ងាចថ្ងៃទី១៨ ខែធ្នូ សមមិត្ត Souphanouvong សមាជិកការិយាល័យនយោបាយនៃគណៈកម្មាធិការមជ្ឈិម LPDR, ប្រធានាធិបតី LPDR និងប្រធានឧត្តមក្រុមប្រឹក្សាប្រជាជន LPDR និងជាប្រធានគណៈប្រតិភូបក្ស-រដ្ឋាភិបាលឡាវ ដែលបានបំពេញដំណើរទស្សនកិច្ចសុឆន្ទៈជាផ្លូវការក្នុងកម្ពុជាប្រជាធិបតេយ្យ បានចូលរួមទស្សនាការសំដែងសិល្បៈ ដើម្បីផ្តល់ជាកិត្តយសជូនសមមិត្ត Souphanouvong ដោយក្រុមសិល្បៈបដិវត្តន៍កម្ពុជា នៅសាលមហោស្រព។

សមមិត្ត ខៀវ សំផន ប្រធានគណៈប្រធានរដ្ឋ, ឧបនាយករដ្ឋមន្ត្រី អៀង សារី, រដ្ឋមន្ត្រី អៀង ធីរិទ្ធ និងយ៉ុន យ៉ាត និងឯកអគ្គរដ្ឋទូត សំ សាន បានចូលរួមក្នុងការសំដែងសិល្បៈ ជាមួយភ្ញៀវកិត្តយស។

ចំពោះភាគីឡាវ ដែលបានចូលរួមជាមួយសមមិត្ត Souphanouvong គឺជាសមាជិកទាំងអស់នៃគណៈប្រតិភូ រួមមានសមមិត្ត Phoun Sipaseut ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រី Sanan Southichak, Kou Souvannamethi, Somphavan Inthavong, Khamphai Boupha, Ounheuan Phounsavat និងឯកអគ្គរដ្ឋទូតឡាវ Khamphan Vilachit និងមន្ត្រីនៅស្ថានទូត LPDR។

ចម្រៀងជាច្រើនបទ ព្រមទាំងរបាំកម្ពុជា និងឡាវ ត្រូវបានច្រៀងដោយស្ទាត់ជំនាញ និងដោយរីករាយ និងសំដែងដោយសិល្បៈករ សិល្បៈការនី ដែលធ្វើឲ្យកម្មវិធីនាពេលល្ងាចនោះ ស្ថិតក្នុងបរិយាកាសរីករាយប្រកបដោយមិត្តភាពបដិវត្តន៍ជាភាតរៈដ៏ជ្រាលជ្រៅ និងស្មោះត្រង់ រវាងប្រជាជនទាំងពីរ។

Original EN: 00168307-00168399
[Translated: [00168349], [00168372-00168373]

Formatted
Formatted
Formatted
Formatted
Formatted
Deleted: យ៉ុ
Formatted
Formatted
Formatted
Deleted: និង
Formatted
Deleted: *Unrevised translation. A revised translation will be provided upon request.*

## ដំណើរទស្សនកិច្ចទៅកាន់ក្រុងកំពង់សោម

BK201050Y សេវាព័ត៌មានក្នុងប្រទេស, ប្រទេសកម្ពុជា ម៉ោង០៤00 GMT ថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៧៧ BK

[អត្ថបទ] កាលពីព្រឹកថ្ងៃទី១៩ ខែធ្នូ សមមិត្ត ខៀវ សំផន ប្រធានគណៈប្រធានរដ្ឋ និងសមមិត្តអៀងសារី ឧបនាយករដ្ឋមន្ត្រី បានរួមដំណើរសមមិត្ត Souphanouvong សមាជិកការិយាល័យនយោបាយនៃគណៈកម្មាធិការមជ្ឈិម LPDR, ប្រធានាធិបតី LPDR និងប្រធានឧត្តមក្រុមប្រឹក្សាប្រជាជន LPDR និងជាប្រធានគណៈប្រតិភូបក្ស-រដ្ឋាភិបាលឡាវ បំពេញទស្សនកិច្ចនៅក្រុងកំពង់សោម។

ភ្ញៀវឡាវត្រូវបានទទួលស្វាគមន៍ជាកិត្តយសយ៉ាងកក់ក្តៅនៅអាកាសយានដ្ឋានកេងកង ដោយសមមិត្ត គ្រិន សមមិត្ត គ្រិន អនុលេខាបក្សកុម្មុយនីស្តកម្ពុជាក្រុងកំពង់សោម និងជាអនុប្រធានគណៈកម្មាធិការបម្រើប្រជាជនក្រុងកំពង់សោម និងសមមិត្តឡុញ សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជាក្រុងកំពង់សោម។

នៅក្រុងកំពង់សោម ភ្ញៀវកិត្តយស បានទស្សនាអាគារថ្មីៗនៅកំពង់សោម ដូចជាឃ្លាំងនៅស្ថានីយ៍រថភ្លើង ដែលកម្មករបដិវត្តន៍ បានសាងសង់ និងកំពុងសាងសង់ដោយភាពឆ្នៃប្រឌិតរស់រវើក និងគោលការណ៍ឯករាជ្យ និងភាពម្ចាស់ការលើខ្លួនឯង។

សមមិត្ត Souphanouvong និងសមមិត្តឡាវដទៃទៀត បានពិនិត្យមើលអាគារទាំងនោះ ដោយការយកចិត្តទុកដាក់ និងបានសំដែងការកោតសរសើរចំពោះការតស៊ូ ដែលបង្ហាញដោយកម្មករបដិវត្តន៍ជាភាតរៈ ដើម្បីបំពេញភារកិច្ចរបស់ខ្លួននៅកំពង់ផែ។

កម្មករកំពង់ផែរាប់រយនាក់ ដែលកាន់ទង់ជ័យ និងញញឹមស្វាគមន៍ដ៏កក់ក្តៅចំពោះប្រជាជនឡាវជាបងប្អូន និងភាតរៈបដិវត្តន៍។

Deleted: *Unrevised translation. A revised translation will be provided upon request.*

ក្រោយមក ភ្ញៀវឡាវ បានទស្សនាក្រុងកំពង់សោម និងឆ្នេរខ្សាច់ពីលើរថយន្ត និងបានធ្វើដំណើរទស្សនាតំបន់ឆ្នេរ តាមនាវា។

នៅថ្ងៃត្រង់ គណៈកម្មាធិការ ប.ក.ក ក្រុងកំពង់សោម និងគណៈកម្មាធិការបម្រើប្រជាជនក្រុងកំពង់សោម បានរៀបចំពិធីជប់លៀងយ៉ាងស្និទ្ធស្នាល ដើម្បីទទួលស្វាគមន៍សមមិត្ត Souphanouvong និងសមមិត្តឡាវដទៃទៀត។

សមមិត្ត គ្រិន និងសមមិត្ត Souphanouvong បាននិយាយដោយក្តីរីករាយអំពីចំណងមិត្តភាពបដិវត្តន៍ជាភាតរៈ ជាប្រពៃណីដ៏ជ្រាលជ្រៅ ដ៏យូរអង្វែងរវាងប្រជាជននៃប្រទេសទាំងពីរ។

នៅម៉ោង១៤៥០ នៅថ្ងៃដដែលនោះ បន្ទាប់ពីជូនដំណើរដោយសមមិត្តគ្រិន និងសមមិត្តឡុញនៅឯអាកាសយានដ្ឋានកេង កង ភ្ញៀវឡាវជាបងប្អូន បានត្រឡប់ទៅភ្នំពេញដោយសុវត្ថិភាព។

## ការធ្វើដំណើរទៅកាន់សៀមរាប ក្នុងដំណើរធ្វើមាតុភូមិនិវត្តន៍

BK210846Y សេវាព័ត៌មានក្នុងប្រទេស, ប្រទេសកម្ពុជា ម៉ោង២៣00GMT ថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៧៧ BK

[អត្ថបទ] កាលពីព្រឹកថ្ងៃទី២០ ខែធ្នូ សមមិត្ត Souphanouvong សមាជិកការិយាល័យនយោបាយនៃគណៈកម្មាធិការមជ្ឈិម LPDR, ប្រធានាធិបតី LPDR និងប្រធានឧត្តមក្រុមប្រឹក្សាប្រជាជន LPDR និងជាប្រធានគណៈប្រតិភូបក្ស-រដ្ឋាភិបាលឡាវ បានចាកចេញពីភ្នំពេញ តាមយន្តហោះពិសេស សម្រាប់ដំណើរទស្សនកិច្ចទៅកាន់សៀមរាប-អង្គរ មុនបន្តការធ្វើដំណើរមាតុភូមិនិវត្តន៍ បន្ទាប់ពីបានបំពេញទស្សនកិច្ចជាមិត្តភាពជាផ្លូវការប្រកបដោយជោគជ័យមកកាន់កម្ពុជាប្រជាធិបតេយ្យ។

សមមិត្ត ខៀវ សំផន ប្រធានគណៈប្រធានរដ្ឋ និងសមមិត្តអៀងសារី ឧបនាយករដ្ឋមន្ត្រី បានរួមដំណើរភ្ញៀវជាកិត្តយសឡាវក្នុងដំណើរទស្សនកិច្ចនៅសៀមរាប-អង្គរ។

Deleted: *Unrevised translation. A revised translation will be provided upon request.*

Original EN: 00168307-00168399
[Translated: [00168349], [00168372-00168373]]

នៅពីមុខវិមានភ្ញៀវរបស់រដ្ឋ ទីកន្លែងស្នាក់នៅរបស់ភ្ញៀវបក្ស-រដ្ឋាភិបាលឡាវ មានប្រជាជនរាប់រយនាក់ កាន់ផ្កា និងទង់ជាតិនៃប្រទេសទាំងពីរ ឈរនៅសងខាងផ្លូវ ជាការជូនដំណើរសមមិត្ត Souphanouvong និងសមមិត្តឡាវដទៃទៀត។

សមមិត្ត ខៀវ សំផន, អៀង សារី, ង៉ៀង ធីរិទ្ធ និងយ៉ុន យ៉ាត បានធ្វើដំណើរតាមរថយន្តជាមួយភ្ញៀវកិត្តយសឡាវពីវិមានភ្ញៀវរដ្ឋទៅកាន់អាកាសយានដ្ឋានពោធិ៍ចិនតុង។ នៅទីនោះ សមមិត្ត Souphanouvong និងសមមិត្តឡាវដទៃទៀត ត្រូវបានទទួលស្វាគមន៍ដោយសមមិត្ត នួន ជា អនុលេខាប.ក.ក និងជាប្រធាន CPRA, ឧបនាយករដ្ឋមន្ត្រី វ៉ន វ៉េត, ប្រធានគណៈកម្មាធិការរដ្ឋ ម៉ី ប្រាង និងចេង អន និងរដ្ឋមន្ត្រី ជួន ជឿន។

នៅអាកាសយានដ្ឋានពោធិ៍ចិនតុង ដែលមានការតុបតែងដោយទង់ជាតិកម្ពុជា និងឡាវ ពិធីដ៏អធិកអធម ត្រូវបានធ្វើឡើងដើម្បីជាកិត្តយសដល់សមមិត្ត Souphanouvong និងគណៈប្រតិភូបក្ស-រដ្ឋាភិបាលឡាវជាភាតរៈ។

ពេលនោះ សមមិត្តប្រធានាធិបតី Souphanouvong បានដើរឆ្ពោះទៅអ្នកជូនដំណើររាប់ពាន់នាក់ ដែលបានស្រែកហោរ និងគ្រវីបាច់ផ្កា និងទង់ជ័យនៃប្រទេសទាំងពីរ។ ពួកគេជូនពរសមមិត្តប្រធានាធិបតី Souphanouvong និងសមមិត្តឡាវដទៃទៀត នៅក្នុងគណៈប្រតិភូ ធ្វើដំណើរមាតុភូមិនិវត្តន៍ដោយសុវត្ថិភាព និងស្នើឲ្យពួកគាត់ពាំនាំមិត្តភាពជាបងប្អូនដ៏ជ្រាលជ្រៅបំផុតពីប្រជាជនកម្ពុជាទៅកាន់ប្រជាជនឡាវជាបងប្អូន។ ពួកគេកាន់បដាជាច្រើនដែលសរសេរជាភាសាកម្ពុជា និងឡាវថា "ជយោ! មិត្តភាពបដិវត្តន៍ជាភាតរៈរវាងប្រជាជនកម្ពុជា និងប្រជាជនឡាវ"។

សមមិត្ត Souphanouvong សមមិត្តឡាវដទៃទៀត បានជម្រាបលាមហាជន ក្នុងកាយវិការពោរពេញដោយមនោសញ្ចេតនា និងការគោរពយ៉ាងកក់ក្ដៅ។

កម្មាភិបាលមួយចំនួននៃកងទ័ពបដិវត្តន៍កម្ពុជា និងកម្មាភិបាលនៃក្រសួងនានា ក៏មានវត្តមាននៅអាកាសយានដ្ឋានពោធិ៍ចិនតុងផងដែរ ដើម្បីជូនដំណើរសមមិត្តឡាវដទៃទៀត សមមិត្តប្រធានាធិបតី Souphanouvong និងគណៈប្រតិភូបក្ស-រដ្ឋាភិបាលឡាវជាបងប្អូន។ អង្គទូតនានា និងភរិយារបស់ពួកគេ ក៏មានវត្តមានផងដែរ។

Formatted: Condensed by 0.2 pt

Deleted: *Unrevised translation. A revised translation will be provided upon request.*

Original EN: 00168307-00168399
[Translated: [00168349], [00168372-00168373]]